**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ : ០៩៧ ប្រក កសក .

# ប្រកាស

## ស្តីពី

## វិធាននៃការគ្រប់គ្រង និង ប្រើប្រាស់ឈ្មោះត្រារដ្ឋបាលព្រៃឈើកម្ពុជា

### រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការប្តូរឈ្មោះនាយកដ្ឋានរុក្ខា-ប្រមាញ់ ទៅជារដ្ឋបាលព្រៃឈើ
- បានឃើញប្រកាសលេខ ៥០៩ ប្រក.កសក.បុ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលព្រៃឈើ
- បានឃើញការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

## សម្រេច

**ប្រការ ១ :** អនុញ្ញាតឱ្យរដ្ឋបាលព្រៃឈើគ្រប់ថ្នាក់ប្រើប្រាស់ញញួរត្រារដ្ឋបាលព្រៃឈើកម្ពុជា ធ្វើអំពីលោហធាតុរឹង រាងដូចពូថៅ ខាងខ្នងរាងរង្វង់មូល ហើយបង្កើតស្លាករាងរង្វង់ដែលមានចរិកអក្សរកាត់ **រ.ឥ.** ភ្ជាប់នឹងលេខរៀងក្រោមតួអក្សរនោះ សម្រាប់វាយត្រាលើសាច់ឈើជាសំគាល់ ។

អត្តសញ្ញាណ និងទំហំនៃញញួរត្រារដ្ឋបាលព្រៃឈើ ត្រូវកំណត់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមសំណើរបស់ប្រធានរដ្ឋបាលព្រៃឈើ និងត្រូវបានរក្សាតំកល់ទុកនៅរដ្ឋបាលព្រៃឈើ ។

**ប្រការ ២ :** មុននឹងដាក់ឱ្យប្រើប្រាស់ញញួរត្រារដ្ឋបាលព្រៃឈើកម្ពុជា រដ្ឋបាលព្រៃឈើត្រូវធ្វើកំណត់ហេតុផ្តិតស្លាមញញួរត្រានេះ ហើយយកទៅតំកល់ទុកជាគំរូតាងនៅក្រសួងមហាផ្ទៃ និង តុលាការខេត្ត ក្រុង ។

**ប្រការ ៣ :** អនុញ្ញាតឱ្យប្រើប្រាស់ញញួរត្រារដ្ឋបាលព្រៃឈើកម្ពុជា តាមវិធានដូចខាងក្រោម :

១- ចំពោះឈើហ៊ុបដែលបានមកពីការប្រមូលផលស្របច្បាប់ក្នុងព្រៃគុប មន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ចត្រូវវាយត្រាចំនួនមួយ(១) ជាសម្គាល់នៅត្រង់គល់ និង ចុងឈើហ៊ុប ដើម្បីកំណត់ថាឈើហ៊ុបនេះត្រូវបានមន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ច ពិនិត្យ វាស់វែង និងវាយតម្លៃ ចុះក្នុងកំណត់ហេតុបញ្ជីសៀវភៅ **ត** រួចហើយ ។ ក្រោយពេលដែលព្រៃសម្បទានិក ឬ ម្ចាស់ព្រៃគុបបានបង់ថ្លៃសួយសារ និង បុព្វលាភលើឈើហ៊ុបខាងលើតាមវិធានកំណត់រួចហើយ មន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ចត្រូវវាយនូវត្រាចំនួនបី (៣) បន្ថែមទៅលើកន្លែងដែលមានស្លាមញញួរត្រាមួយ (១) ដើម្បីបង្គប់បួន (៤) លើឈើហ៊ុបនោះ មុនពេលដឹកជញ្ជូនចេញពីគំនរឈើក្នុងព្រៃគុបឆ្ពោះទៅទិសដៅប្រើប្រាស់ ។

២- ចំពោះឈើហ៊ុបល្មើសច្បាប់ ដែលមន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ចចាប់ឃាត់ ត្រូវវាយត្រាលើបី (៣) កន្លែង គឺនៅត្រង់ គល់ កណ្តាល និងចុងហ៊ុប ដែលកន្លែងនីមួយៗត្រូវមានស្លាមញញួរត្រាចំនួនបី (៣) ផ្តុំជារាងត្រីកោណ ដើម្បីបញ្ជាក់ថា ឈើហ៊ុបនេះជាឈើល្មើសច្បាប់ត្រូវចាប់ឃាត់ទុកដើម្បីដោះស្រាយតាមនីតិវិធី ។ ក្រោយពេលដែលករណីបទល្មើសត្រូវបានដោះស្រាយរួចតាមរយៈរដ្ឋបាលព្រៃឈើ ឬតុលាការ មុននឹងដឹកជញ្ជូនទៅទិសដៅផ្សេងទៀត មន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ច ត្រូវវាយញញួរត្រាបន្ថែមឱ្យមានស្លាមចំនួនបួន (៤) ឡើងទៅ គិតទាំងស្លាមចាស់ ។

**ប្រការ ៤ :** មន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ចដែលបានធ្វើសច្ចាប្រណិធាន ត្រូវបានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ចេញសេចក្តីសម្រេចប្រគល់សិទ្ធិឱ្យកាន់កាប់ និង ប្រើប្រាស់ញញួរត្រារដ្ឋបាលព្រៃឈើកម្ពុជា តាមសំណើរបស់ប្រធានរដ្ឋបាលព្រៃឈើ ។

មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលសិទ្ធិកាន់កាប់ និងប្រើប្រាស់ញញួរត្រារដ្ឋបាលព្រៃឈើកម្ពុជា ត្រូវមានប្រកាសប្រើប្រាស់ដោយផ្ទាល់ ហើយប្រើបានតែក្នុងករណីស្របច្បាប់ប៉ុណ្ណោះ ។

**ប្រការ ៥ :** ក្នុងករណីមានការផ្ទេរសិទ្ធិកាន់កាប់ និង ប្រើប្រាស់ញញួរត្រារដ្ឋបាលព្រៃឈើកម្ពុជា ប្រធានរដ្ឋបាលព្រៃឈើ ត្រូវធ្វើសំណើទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដើម្បីចេញសេចក្ដីសម្រេចប្រគល់សិទ្ធិជាថ្មី។

**ប្រការ ៦ :** មន្ត្រីរដ្ឋបាលព្រៃឈើណាដែលយកញញួរត្រារដ្ឋបាលព្រៃឈើកម្ពុជា ទៅប្រើប្រាស់ខុសច្បាប់ ឬ ផ្ទុយនឹងវិធានកំណត់ក្នុងប្រកាសនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

**ប្រការ ៧ :** ក្នុងករណីបាត់ញញួរត្រារដ្ឋបាលព្រៃឈើកម្ពុជា មន្ត្រីរដ្ឋបាលព្រៃឈើសាមីត្រូវរាយការណ៍ជាបន្ទាន់ទៅរដ្ឋបាលព្រៃឈើតាមឋានានុក្រម និង ទៅអាជ្ញាធរមានសមត្ថកិច្ចដែលនៅជិតបំផុត ដើម្បីចាត់វិធានការតាមផ្លូវច្បាប់ ។

ប្រធានរដ្ឋបាលព្រៃឈើ ត្រូវចេញសេចក្ដីជូនដំណឹងបញ្ចប់សុពលភាពនៃញញួរត្រាដែលបាត់ និង ត្រូវរាយការណ៍ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អំពីហេតុការណ៍បាត់ញញួរត្រានេះ ដោយបញ្ជាក់ពីមូលហេតុច្បាស់លាស់ ។

**ប្រការ ៨ :** ប្រកាស ឬ សេចក្ដីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៩ :** អគ្គនាយកនៃក្រសួង អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធានរដ្ឋបាលព្រៃឈើ និងប្រធានអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដែលពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ . ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៥

រដ្ឋមន្ត្រី

ចាន់ សារុន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងយុត្តិធម៌
- តុលាការខេត្ត ក្រុង
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- គ្រប់សាលាខេត្ត ក្រុង
- ដូចប្រការ ៩
- ឯកសារ-កាលប្បវត្តិ